00640420

F1/6

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

គោរពជូនអង្គជំនុំជម្រះតុលាការកំពូល

ឯកឧត្តម គង់ ស្រីម

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម ស៊ិន រិទ្ធ

ចៅក្រម យ៉ា ណារិន

ចៅក្រម Mottoo NOGUCHI

ចៅក្រម Agnieszka KLONOWIECKA-MILART

ចៅក្រម Chandra NIHAL JAYASINGHE

ឯកសារបានទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 28 / 01 / 2011
ម៉ោង (Time/Heure): 9:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១០

**កម្មវត្ថុ៖ អង្គភាពគាំពារការការពារក្ដី ស្នើសុំអង្គជំនុំជម្រះតុលាការកំពូលអនុវត្តអំណាចរបស់ខ្លួន ក្រោមវិធាន ៣៣ នៃវិធានផ្ទៃក្នុងរបស់ អវតក**

លោកចៅក្រមជាទីគោរព!

**សេចក្ដីផ្ដើម៖**

1. បើតាមការដាក់សារណានៃបណ្ដឹងសារទុក្ខ និងចម្លើយតបនានានៅក្នុងដំណើរការនីតិវិធីនៃបណ្ដឹងសារទុក្ខទាក់ទងនឹងលោក កាំង ហ្កេកអ៊ាវ ហៅ ឌុច ("ជនជាប់ចោទ") មន្ត្រីទទួលបន្ទុកនៃអង្គភាពគាំពារការការពារក្ដី ("DSS") នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អវតក") កត់សម្គាល់ថា សហមេធាវីរបស់ជនជាប់ចោទ ("សហមេធាវី") មិនបានលើកឡើងនូវបញ្ហាច្បាប់ជាច្រើនដែលត្រូវបានលើកនៅក្នុងបណ្ដឹងសារទុក្ខរបស់សហព្រះរាជអាជ្ញាឡើយ ។ ដោយកត់សម្គាល់សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១០[1] អង្គភាព

[1] សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើសំណើរបស់អង្គភាពគាំពារការការពារក្ដី ស្នើសុំដាក់សារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្ដីមកកាន់អង្គជំនុំជម្រះតុលាការកំពូល, សំណុំរឿង ០០១/១៨-០៧-២០០៧-អវតក/អជតក អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១០ F7/2, ("សេចក្ដីសម្រេចលើសំណើរបស់អង្គភាព DSS") ។

F16

DSS ស្នើសុំដោយគោរពថា ដោយអនុលោមតាមវិធាន ៣៣ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះតុលាការកំពូលពិចារណាអញ្ជើញអង្គការ ឬ បុគ្គលឯករាជ្យដែលសក្តិសម ឱ្យដាក់សារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី ដើម្បីធានាថារាល់បញ្ហាច្បាប់ដែលពាក់ព័ន្ធទាំងអស់ទទួលបានការបង្ហាញយ៉ាងពេញលេញនៅក្នុងនីតិវិធីបណ្តឹងសារទុក្ខបច្ចុប្បន្ននេះ ។

**សាវតារ**

2. នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ជនជាប់ចោទម្នាក់ត្រូវបានផ្តន្ទាទោសដោយអង្គជំនុំជម្រះសាលាដំបូងរបស់ អវតក[2]។ នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១០ សហមេធាវីបានដាក់ការជូនដំណឹងពីបណ្តឹងសារទុក្ខរបស់ពួកគេ[3] ។ បើតាមការជូនដំណឹងពីបណ្តឹងសារទុក្ខ សហមេធាវីមានបំណងកម្រិតអំណះអំណាងត្រឹមបញ្ហាដែលទាក់ទងនឹងយុត្តាធិការបុគ្គលរបស់ អវតក តែប៉ុណ្ណោះ ។

3. លោក Richard Rogers អតីតប្រធានអង្គភាព DSS នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១០ បានដាក់សំណើសុំការអនុញ្ញាតពីអង្គជំនុំជម្រះតុលាការកំពូល ដើម្បីដាក់សារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី ដើម្បីលើកឡើងនូវបញ្ហានៃការផ្តន្ទាទោសដាក់ពន្ធនាគារ និងដើម្បីធានាថាអង្គជំនុំជម្រះតុលាការកំពូល "ត្រូវបានជូនដំណឹងយ៉ាងពេញលេញពីទិដ្ឋភាពជាក់លាក់នៃច្បាប់អន្តរជាតិ ("សំណើរបស់អង្គភាព DSS")[4] ។

4. សហព្រះរាជអាជ្ញានៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០ បានដាក់ចម្លើយតបទៅនឹងសំណើរបស់អង្គភាព DSS ដែលបានប្រឆាំងនឹងភាពអាចទទួលយកបានសំណើរបស់អង្គភាព DSS[5] ។ សហព្រះរាជអាជ្ញាបានទាញជាទឡ្ហីករណ៍ថា សារណាបែបនេះនឹងផ្ទុយពីវិធានផ្ទៃក្នុងនានារបស់ អវតក ហើយនឹងបង្កើតឱ្យមានទំនាស់ផលប្រយោជន៍ និងខ្វះឯករាជ្យភាពដែលតម្រូវមាន ។

---

[2] សំណុំរឿង ០០១/១៨-០៧-២០០៧-អវតក/អជសង សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, E188 ។

[3] ការជូនដំណឹងពីបណ្តឹងសារទុក្ខរបស់សហមេធាវី ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងកិច្ចការណីកាំង ហ្កេកអ៊ាវ ហៅ ឌុច សំណុំរឿង ០០១/១៨-០៧-២០០៧-អវតក/អជសង ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១០ E188/2 ។

[4] សំណើរបស់អង្គភាព DSS សុំដាក់សារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី សំណុំរឿង ០០១/១៨-០៧-២០០៧-អវតក/អជសង, អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០, ឯកសារ E7 ។

[5] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់អង្គភាព DSS សុំដាក់សារណារបស់អ្នកដែលមិនមែនជាគូភាគីក្នុងរឿងក្តី ទៅអង្គជំនុំជម្រះតុលាការកំពូល សំណុំរឿង ០០១/១៨-០៧-២០០៧-អវតក/អជសង, អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០, ឯកសារ E7/2 ("ចម្លើយតបរបស់សហព្រះរាជអាជ្ញា") ។

5. ប៉ុន្តែសហព្រះរាជអាជ្ញាបានថ្លែងថាពួកគេ "គាំទ្រនូវការអញ្ជើញឲ្យមានការដាក់សារណារបស់អ្នកដែលមិនមែនជាគូភាគីក្នុងរឿងក្តី ពីសំណាក់ភាគីទីបីដ៏សក្តិសមឯករាជ្យមួយ នៅពេលណាដែលអង្គជំនុំជម្រះតុលាការកំពូលមានលទ្ធភាពសម្រេចភាពចាំបាច់ និងវិសាលភាពនៃជំនួយផ្នែកច្បាប់បន្ថែម ក្រោយពីការអានសារណា និងចម្លើយតបរបស់ភាគីទាំងអស់រួចហើយ"[6] ។

6. នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១០ សហព្រះរាជអាជ្ញាបានដាក់សារណានៃបណ្តឹងសារទុក្ខរបស់ខ្លួនប្រឆាំងនឹងសាលដីការបស់អង្គជំនុំជម្រះសាលាដំបូង ។ សហព្រះរាជអាជ្ញាបានប្តឹងជំទាស់ទៅនឹងចំនុចជាច្រើន រួមទាំងចំនុចដែលថាអង្គជំនុំជម្រះសាលាដំបូងភាន់ច្រឡំក្នុងការអនុវត្តឆន្ទានុសិទ្ធិក្នុងការផ្តន្ទាទោសរបស់ខ្លួន ដោយបានផ្តន្ទាទោសដាក់ក្នុងពន្ធនាគារស្រាលពេក ។ សហព្រះរាជអាជ្ញាក៏បានប្តឹងជំទាស់ទៅនឹងចំនុចដែលថា អង្គជំនុំជម្រះសាលាដំបូងភាន់ច្រឡំក្នុងការផ្តន្ទាទោសជនជាប់ចោទចំពោះតែឧក្រិដ្ឋកម្មទាំងឡាយណា ដែលត្រូវបានរកឃើញថាគាត់ទទួលខុសត្រូវ ហើយថាជនជាប់ចោទមិនត្រូវបានផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មនៃការធ្វើឲ្យទៅទាសករទៅលើអ្នកទោសទាំងអស់នៅមន្ទីរស-២១ ឡើយ ។

7. សហមេធាវីជ្រើសរើសមិនឆ្លើយតបទៅនឹងសារណាបណ្តឹងសារទុក្ខរបស់សហព្រះរាជអាជ្ញា ហើយមកដល់ពេលនេះ សហមេធាវីមិនបានលើកនូវទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាទាក់ទងនឹងភាពសមល្មមនៃការផ្តន្ទាទោស ប្រឆាំងមកលើជនជាប់ចោទ ។

8. នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១០ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធសំណើរបស់អង្គភាព DSS នៅក្នុងសេចក្តីសម្រេចចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១០ ដែលចែងថាសារណារបស់អ្នកដែលមិនមែនជាគូភាគីក្នុងរឿងក្តី "មិនត្រូវពាក់ព័ន្ធជាមួយតុលាការ ឬ ស្ថាប័នណាមួយរបស់តុលាការឡើយ"[7] ។

### ភាពចាំបាច់ និងវិសាលភាពនៃជំនួយរបស់អ្នកដែលមិនមែនជាគូភាគីក្នុងរឿងក្តី (amicus curiae)

9. មកដល់ពេលនេះ សហមេធាវីផ្តោតការយកចិត្តទុកដាក់ទាំងស្រុងតែទៅលើបញ្ហាយុត្តាធិការបុគ្គលនៅក្នុងនីតិវិធីបណ្តឹងសារទុក្ខ ដោយមិនបានលើកឡើងនូវបញ្ហាផ្នែកច្បាប់នានាដែលត្រូវបានលើកឡើងនៅក្នុងបណ្តឹងសារទុក្ខរបស់សហព្រះរាជអាជ្ញា ។ ជាលទ្ធផល បញ្ហាផ្នែកច្បាប់នានាដែល

---

[6] ចម្លើយតបរបស់សហព្រះរាជអាជ្ញា នៅកថាខណ្ឌទី ១២ ។

[7] ចម្លើយតបរបស់សហព្រះរាជអាជ្ញា នៅកថាខណ្ឌទី ៧ ។

F16

ពាក់ព័ន្ធ នឹងមិនទំនងជាត្រូវបានបង្ហាញឱ្យបានពេញលេញនោះទេ ជាពិសេសបញ្ហាទាក់ទងនឹងការផ្តន្ទាទោសដាក់ពន្ធនាគារនេះ ។

10. ម្យ៉ាងវិញទៀត ដំណើរការនីតិវិធីបណ្តឹងសារទុក្ខបច្ចុប្បន្ន នឹងត្រូវសម្រេចលើកដំបូងបង្អស់ដោយអង្គជំនុំជម្រះតុលាការកំពូល ។ ហេតុដូច្នេះ បញ្ហាច្បាប់ព្រហ្មទណ្ឌអន្តរជាតិថ្មីៗ និងស្មុគស្មាញជាច្រើននឹងត្រូវលើកឡើង និងសម្រេចជាលើកដំបូង ។ សាលដីកានឹងបង្កើតជាយុត្តិសាស្ត្រដែលនឹងមានឥទ្ធិពលលើការជំនុំជម្រះក្តីទាំងអស់នៅ អវតក នាថ្ងៃអនាគត ។ ហេតុដូច្នេះ វាជាការចាំបាច់ដែលថារាល់បញ្ហាច្បាប់ដែលពាក់ព័ន្ធទាំងអស់ ទទួលបានការបង្ហាញយ៉ាងពេញលេញ ដើម្បីជួយដល់អង្គជំនុំជម្រះតុលាការកំពូលសម្រេចលើបណ្តឹងសារទុក្ខនេះឱ្យបានត្រឹមត្រូវ ។

11. "ប្រសិនបើអង្គជំនុំជម្រះពិចារណាថាអង្គជំនុំជម្រះចង់សម្រេចលើករណីឱ្យបានត្រឹមត្រូវ" នោះអង្គជំនុំជម្រះអាចអញ្ជើញឱ្យមានការដាក់សារណាពីសំណាក់ amicus curiae លើបញ្ហាទាំងឡាយណាដែលកំណត់ដោយអង្គជំនុំជម្រះ"[8] ។ អង្គជំនុំជម្រះក៏មានអំណាចស្នើសុំឱ្យ amicus curiae លើកអំណះអំណាងដែលជាផលប្រយោជន៍ដល់ភាគីជាក់លាក់ ដែលមធ្យោបាយនេះបំរើផលប្រយោជន៍ខាងយុត្តិធម៌[9] ។ ឧទាហរណ៍ អង្គជំនុំជម្រះតុលាការកំពូលនៅតុលាការ ("ICTY") សម្រេចតែងតាំង amicus curiae ដើម្បីធ្វើការដោយឯករាជ្យពីជនជាប់ចោទ និង"ដើម្បីដាក់ទឡ្ហីករណ៍នៃបណ្តឹងឧទ្ធរណ៍ ដោយស្វែងរកឱ្យមានការប្រានចោលការផ្តន្ទាទោស ឬ កាត់បន្ថយទោសជាប់ពន្ធនាគារ និងដើម្បីលើកអំណះអំណាង ប្រឆាំងនឹងទឡ្ហីករណ៍បណ្តឹងឧទ្ធរណ៍ ដែលដាក់ដោយរដ្ឋអាជ្ញា"[10] ។

---

[8] *ករណីរដ្ឋអាជ្ញា តទល់ជាមួយ Momcilo Krajisnik*, សំណុំរឿងលេខ IT-00-39-A សេចក្តីសម្រេចលើសំណើរបស់ Momcilo Krajisnik, សុំការពារដោយខ្លួនឯង និងលើញត្តិរបស់មេធាវីទាក់ទងនឹងការចាត់តាំងអ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី និងលើញត្តិរបស់រដ្ឋអាជ្ញា ចុះថ្ងៃទី១៦ ខែកុម្ភះ ឆ្នាំ២០០៧, ១១ ខែ ឧសភា ឆ្នាំ២០០៧ នៅកថាខណ្ឌទី១៧ ។

[9] *ករណីរដ្ឋអាជ្ញា តទល់ជាមួយ Slobodan Miloservic,* សំណុំរឿងលេខ IT-02-54-AR73.6, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំ ដែលដាក់ដោយសារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី ប្រឆាំងនឹងដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងការតំណាង និងការៀបចំករណីរបស់មេធាវីការពារក្តី ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៤ នៅកថាខណ្ឌទី១៩ ។

[10] *ករណីរដ្ឋអាជ្ញា តទល់ជាមួយ Momcilo Krajisnik,* សំណុំរឿងលេខ IT-00-39-Aសេចក្តីសម្រេចលើសំណើរបស់ Momcilo Krajisnik, សុំការពារដោយខ្លួនឯង និងលើញត្តិរបស់មេធាវីទាក់ទងនឹងការចាត់តាំងអ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី និងលើញត្តិរបស់រដ្ឋអាជ្ញា ចុះថ្ងៃទី១៦ ខែកុម្ភះ ឆ្នាំ២០០៧, ១១ ខែ ឧសភា ឆ្នាំ២០០៧ នៅកថាខណ្ឌទី១៩ ។

F16

12. ដោយសារតែ amicus curiae គឺជាអ្នកដែលមិនមែនជាភាគីក្នុងនីតិវិធី អង្គជំនុំជម្រះពុំមានកាតព្វកិច្ចដោះស្រាយអំណះអំណាងទាំងអស់ដែលលើកឡើងដោយ amicus curiae ឡើយ ។ ប៉ុន្តែ អង្គជំនុំជម្រះមានអំណាចពិនិត្យអំណះអំណាងដែលលើកឡើងដោយ amicus curiae ដើម្បីវាយតម្លៃថាតើផលប្រយោជន៍ខាងយុត្តិធម៌ តម្រូវឱ្យអង្គជំនុំជម្រះពិចារណា តាមគំនិតផ្តួចផ្តើមរបស់ខ្លួន លើបញ្ហាដែលមិនត្រូវបានលើកឡើងនៅក្នុងបណ្តឹងសារទុក្ខរបស់ជនជាប់ចោទ ឬនៅក្នុងចម្លើយតបរបស់គាត់ទៅនឹងបណ្តឹងសារទុក្ខរបស់រដ្ឋអាជ្ញា[11] ។

13. ស្របតាមការអនុវត្តនៅកម្រិតអន្តរជាតិ អវតក បានទទួលសារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តីជាច្រើន ។ ឧទាហរណ៍ អង្គបុរេជំនុំជម្រះបានអញ្ជើញអង្គការនានាឱ្យដាក់សារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី ដើម្បីជួយដល់អង្គបុរេជំនុំជម្រះសម្រេចលើបញ្ហានៃការឃុំខ្លួនបណ្តោះអាសន្ន”[12] អង្គបុរេជំនុំជម្រះបានអញ្ជើញសាស្ត្រាចារ្យ Antonio Cassese, សាស្ត្រាចារ្យ Kai Ambos, និង the McGill Centre for Human Rights and Legal pluralism ឱ្យដាក់សារណាទាក់ទងនឹងភាពអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួម[13]។ អង្គបុរេជំនុំជម្រះក៏បានអញ្ជើញឱ្យមានដាក់សារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តីពីសំណាក់អង្គការនានា និងសាធារណជនលើបញ្ហានៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី[14] ។

14. មន្ត្រីទទួលបន្ទុកនៃអង្គភាព DSS កត់សម្គាល់ថាសហព្រះរាជអាជ្ញាជំទាស់នឹងសំណើរបស់អង្គភាព DSS លើទឡ្ហីករណ៍ដែលថា អនុលោមតាមវិធានផ្ទៃក្នុង អង្គភាព DSS មិនត្រូវបានអនុញ្ញាតឱ្យដាក់សារណា អង្គជំនុំជម្រះឡើយ, សារណាពីអង្គភាព DSS អាចបង្កើតនូវទំនាស់ផល

---

[11] *ករណីរដ្ឋអាជ្ញា តទល់ជាមួយ Momcilo Krajisnik,* សំណុំរឿងលេខ IT-00-39-Aសេចក្តីសម្រេចលើសំណើរបស់ Momcilo Krajisnik, សុំការពារដោយខ្លួនឯង និងលើញត្តិរបស់មេធាវីទាក់ទងនឹងការចាត់តាំងអ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី និងលើញត្តិរបស់រដ្ឋអាជ្ញា ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៧, ១១ ខែ ឧសភា ឆ្នាំ២០០៧ នៅកថាខណ្ឌទី២០ ។

[12] (០៧-០៩-០០១ អវតក) អបជ, ការជូនដំណឹង, ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០០៧ ។ (០២-១៩-០៩-២០០៧- អវតក-កសចស), អបជ០១, ការជូនដំណឹង ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៧ ។ (០២-១៩-០៩-២០០៧- អវតក-កសចស), អបជ០២, ការជូនដំណឹង ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៨ ។ (០២-១៩-០៩-២០០៧- អវតក-កសចស), អបជ០៣, ការជូនដំណឹង ចុះថ្ងៃទី ៤ ខែកុម្ភៈ ឆ្នាំ២០០៨ ។

[13] (០០១-១៨-០៧-២០០៧អវតក) អបជ០២, ការជូនដំណឹង ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៧ ។

[14] (០២-១៩-០៩-២០០៧- អវតក-កសចស), អបជ០១, ដីកាបង្គាប់ឱ្យដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីទាក់ទងនឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន និងការអញ្ជើញ amicus curiae ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៨ ។

F16

ប្រយោជន៍ជាមួយក្រុមការពារក្តីរបស់ជនជាប់ចោទ ហើយអង្គភាព DSS មិនមានឯករាជ្យភាពដែលតម្រូវដើម្បីដាក់សាររបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី[15] ។ អង្គជំនុំជម្រះក៏យល់ឃើញដែរថាការដាក់សារណាបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តីពីសំណាក់អង្គភាព DSS ហួសពីអាណត្តិរបស់ខ្លួន[16] ។

15. ពុំមានលេចឡើងពីការព្រួយបារម្ភបែបនេះ ទាក់ទងនឹងការដាក់សារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តីពីសំណាក់អង្គការ ឬបុគ្គលឡើយ ។ ជាការពិត សហព្រះរាជអាជ្ញាបានសម្តែងនូវការគាំទ្ររបស់ពួកគេក្នុងការអញ្ជើងឲ្យមានការដាក់សារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី ពីសំណាក់ភាគីទីបីដ៏សក្តិសមឯករាជ្យមួយ នៅពេលណាដែលអង្គជំនុំជម្រះតុលាការកំពូលមានលទ្ធភាពសម្រេចភាពចាំបាច់ និងវិសាលភាពនៃជំនួយផ្នែកច្បាប់បន្ថែម ក្រោយពីការអានសារណា និងចម្លើយតបរបស់ភាគីទាំងអស់រួចហើយ”[17] ។ ពេលនេះសារណាបណ្តឹងសារទុក្ខទាំងអស់ និងចម្លើយតបនានា ត្រូវបានដាក់រួចហើយ មន្ត្រីទទួលបន្ទុកនៃអង្គភាព DSS ស្នើសុំដោយគោរពថាភាពចាំបាច់ និងវិសាលភាពនៃជំនួយផ្នែកច្បាប់នេះ អាចជួយដល់ការធ្វើសេចក្តីសម្រេច ។

## សំណើ

16. សម្រាប់ហេតុផលដែលបានបញ្ជាក់នៅទីនេះ មន្ត្រីទទួលបន្ទុកនៃអង្គភាព DSS ស្នើសុំដោយគោរពដល់អង្គជំនុំជម្រះតុលាការកំពូលឲ្យអនុវត្តអំណាចរបស់ខ្លួន ក្រោមវិធាន ៣៣ នៃវិធានផ្ទៃក្នុង និងអញ្ជើញឲ្យមានការដាក់សារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី ពីសំណាក់អង្គការ ឬបុគ្គល ដើម្បីធានាថាអំណះអំណាងផ្នែកច្បាប់ទាក់ទងនឹងបញ្ហានានា ដែលលើកឡើងនៅក្នុងបណ្តឹងសារទុក្ខរបស់សហព្រះរាជអាជ្ញា ហើយមកដល់ពេលនេះ មិនត្រូវបានលើកឡើងដោយសហមេធាវីនៅក្នុងនីតិវិធី ជាពិសេស បញ្ហានៃការផ្តន្ទាទោសដាក់ពន្ធនាគារ ត្រូវបានបង្ហាញយ៉ាងពេញលេញ ។

ដោយការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ

---

[15] ចម្លើយតបរបស់សហព្រះរាជអាជ្ញា នៅកថាខណ្ឌទី២,៣ និងទី៥ ។

[16] សេចក្តីសម្រេចលើសំណើរបស់អង្គភាព DSS នៅកថាខណ្ឌទី៩។

[17] ចម្លើយតបរបស់សហព្រះរាជអាជ្ញា នៅកថាខណ្ឌទី ១២ ។

00640426

F16

Rupert Abbott

**មន្ត្រីទទួលបន្ទុក**

**អង្គភាពគាំពារការការពារក្តី**

